លេខ ៣០ ចេញផ្សាយថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៣

# ព្រឹត្តិបត្រព័ត៌មានប្រចាំខែវិច្ឆិកា ឆ្នាំ២០២៣

**និយ័តករបរធនបាលកិច្ច**
**គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ**
**បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា**

## កម្មវិធីបណ្តុះបណ្តាលស្តីពី "ស្តង់ដាប្រតិបត្តិផ្ទៃក្នុងសម្រាប់ការអនុវត្តគោលការណ៍ប្រតិបត្តិការ និងការធានាឥណទាននៃគម្រោង ACSEP សមាសភាគទី១"

នាថ្ងៃពុធ ៣រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១ខែវិច្ឆិកា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាប្រធានគ្រប់គ្រងគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP) សម្រាប់សមាសភាពទី១ (PIU1) អញ្ជើញចូលរួមជាអធិបតីក្នុងកម្មវិធីបណ្តុះបណ្តាលស្តីពី "ស្តង់ដាប្រតិបត្តិផ្ទៃក្នុងសម្រាប់ការអនុវត្តគោលការណ៍ប្រតិបត្តិការ និងការធានាឥណទាននៃគម្រោង ACSEP សមាសភាគទី១"។ កម្មវិធីនេះមានការអញ្ជើញចូលរួមដោយ លោក-លោកស្រី ដែលជាប្រធានផ្នែក សមាជិក-សមាជិកានៃអង្គភាពអនុវត្តគម្រោង ACSEP-PIU1 និងក្រុមទីប្រឹក្សាគម្រោង ACSEP-PIU1, និងមានការធ្វើបទបង្ហាញដោយលោកស្រី Marry Miller ទីប្រឹក្សាអន្តរជាតិផ្នែកធានាឥណទាន។



រូបភាព៖ កម្មវិធីបណ្តុះបណ្តាលស្តីពី "ស្តង់ដាប្រតិបត្តិផ្ទៃក្នុងសម្រាប់ការអនុវត្តគោលការណ៍ប្រតិបត្តិការ និងការធានាឥណទាននៃគម្រោង ACSEP សមាសភាគទី១"។

## មាតិកា


- កម្មវិធីបណ្តុះបណ្តាលស្តីពី "ស្តង់ដាប្រតិបត្តិផ្ទៃក្នុងសម្រាប់ការអនុវត្តគោលការណ៍ប្រតិបត្តិការ និងការធានាឥណទាននៃគម្រោង ACSEP សមាសភាគទី១" ទំព័រទី១
- កម្មវិធីចែករំលែកចំណេះដឹងស្តីពី "ចក្ខុវិស័យទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម" ទំព័រទី២
- កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ទំព័រទី២
- កិច្ចការងារសង្គម ទំព័រទី២
- អនុស្សរណៈនៃការយោគយល់គ្នា (MoU) រវាង ន.ប.ធ. និងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ទំព័រទី៣
- វគ្គបណ្តុះបណ្តាលស្តីពី "ការរៀបចំសំណើអាជីវកម្ម" ទំព័រទី៣
- វគ្គបណ្តុះបណ្តាលផ្ទៃក្នុងនិយ័តករបរធនបាលកិច្ចស្តីពី "កាតព្វកិច្ចរាយការណ៍ និងបញ្ជូនករណីសង្ស័យការប្រព្រឹត្តល្មើសពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច" ទំព័រទី៤
- កិច្ចប្រជុំបច្ចេកទេសនៃអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ទំព័រទី៤
- កម្មវិធី "ជជែកអំពីបរធនបាលកិច្ច" ក្រោមប្រធានបទស្តីពី "បរធនបាលកិច្ច÷ យន្តការសម្រាប់ការវិនិយោគលើអចលនទ្រព្យប្រកបដោយទំនុកចិត្ត" ទំព័រទី៥
- វគ្គបណ្តុះបណ្តាលស្តីពី "ការរៀបចំសំណើអាជីវកម្ម" ទំព័រទី៥
- កិច្ចប្រជុំប្រមូលធាតុចូលសម្រាប់រៀបចំយន្តការ, លក្ខខណ្ឌ, នីតិវិធី និងបទដ្ឋានគតិយុត្តដើម្បីលើកទឹកចិត្តដល់វិនិយោគិនបរទេសវិនិយោគលើវិស័យអចលនទ្រព្យនៅកម្ពុជា ទំព័រទី៦
- ពិធីពិព័រណ៍ផ្សារភាគហ៊ុនកម្ពុជា "My First STOCK" ប្រចាំឆ្នាំ២០២៣ ទំព័រទី៦
- សិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការដាក់ឱ្យអនុវត្តជាផ្លូវការម៉ាស៊ីនមេសម្រាប់ការប្រើប្រាស់ផ្ទៃក្នុងរបស់ **ន.ប.ធ.**" និងសេចក្តីណែនាំស្តីពី "ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងឯកសាររបស់ **ន.ប.ធ.**" ក្នុងក្របខណ្ឌនៃការអនុវត្តសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM) ប្រចាំឆ្នាំ២០២៣ ទំព័រទី៦
- កិច្ចប្រជុំពិភាក្សាជាមួយមជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech Center) ទំព័រទី៧
- កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដើម្បីពិនិត្យ និងពិភាក្សាលើរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសទី៣ ឆ្នាំ២០២៣ ទំព័រទី៨
- សិក្ខាសាលាស្តីពី ការរៀបចំ និងការលើកទឹកចិត្តគម្រោងចំណតសាធារណៈ ទំព័រទី៨
- ប្រជុំពិភាក្សាការងាររវាង ន.ប.ធ. និងក្រុមហ៊ុនTrustQuay ទំព័រទី៨
- កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងគោលការណ៍ណែនាំស្តីពី "បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យបរធនបាលកិច្ច" ទំព័រទី៩
- កិច្ចប្រជុំស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាសម្រាប់ឆ្នាំ២០២៤ ទំព័រទី៩
- កម្មវិធីសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ផែនការសកម្មភាពបីឆ្នាំរំកិល ២០២៣-២០២៥ របស់និយ័តករបរធនបាលកិច្ច÷ ការវាយតម្លៃការអនុវត្ត និងទិសដៅការងារបន្ត" និងកម្មវិធីកសាងសមត្ថភាពមន្ត្រី" ទំព័រទី១០
- កម្មវិធីការងារសង្គមនៅ "មជ្ឈមណ្ឌលកុមារកំព្រា ខេត្តសៀមរាប" ទំព័រទី១០
- កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដើម្បីពិនិត្យលើខ្លឹមសារនៃសេចក្តីព្រាងផែនការអភិវឌ្ឍន៍ស្ថាប័ននិយ័តករគណនេយ្យនិងសវនកម្មសម្រាប់រយៈពេល១០ឆ្នាំ (២០២១-២០៣០) ទំព័រទី១១




អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## កម្មវិធីចែករំលែកចំណេះដឹងស្តីពីចក្ខុវិស័យទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម

នារសៀលថ្ងៃពុធ ៣រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រោមក្របខណ្ឌនៃអនុស្សរណៈនៃការយោគយល់គ្នារវាង និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងវិទ្យាស្ថានខេមរអេដ និងដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) មន្ត្រីជំនាញនៃ **ន.ប.ធ.** បានចូលរួមកម្មវិធីចែករំលែកចំណេះដឹងស្តីពី "ចក្ខុវិស័យទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**ឯកឧត្តម ហេម វណ្ណឌី** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៅវិទ្យាស្ថានខេមរអេដ។



**រូបភាព៖** កម្មវិធីចែករំលែកចំណេះដឹងស្តីពី "ចក្ខុវិស័យទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម" នៅវិទ្យាស្ថានខេមរអេដ។

## កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)

នារសៀលថ្ងៃសុក្រ ៥រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **ឯកឧត្តម ណឹ សាគល** អគ្គនាយករងនៃ **ន.ប.ធ.** បានដឹកនាំសហការីចូលរួមកិច្ចប្រជុំកម្រិតបច្ចេកទេសនៃអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) តាមប្រព័ន្ធអនឡាញ (Zoom) ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម វង់ ស៊ីវលន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សា **អ.ស.ហ.** តាមរយៈកិច្ចសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាននៃ **អ.ស.ហ.** ដើម្បីពិនិត្យ និងផ្តល់យោបល់លើឯកសារចំនួន ២ ដូចខាងក្រោម៖

១. សេចក្តីព្រាងប្រកាសស្តីពី "កាតព្វកិច្ចផ្តល់របាយការណ៍ជូនដំណឹង និងស្នើសុំការអនុញ្ញាតរបស់ក្រុមហ៊ុនអភិបាលមូលនិធិ" របស់និយ័តករមូលបត្រកម្ពុជា

២. សេចក្តីព្រាងប្រកាសស្តីពី "កាតព្វកិច្ចផ្តល់របាយការណ៍ជូនដំណឹង និងស្នើសុំការអនុញ្ញាតរបស់បរធនបាល" របស់ **ន.ប.ធ.**។

កិច្ចប្រជុំនេះមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋាន **អ.ស.ហ.** អង្គភាពសវនកម្មផ្ទៃក្នុង និងនិយ័តករក្រោមឱវាទ **អ.ស.ហ.**។



**រូបភាព៖** កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**)។

## កិច្ចការងារសង្គម

នាថ្ងៃសៅរ៍ ៦រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តាមរយៈ **ឯកឧត្តម នង ពិសិដ្ឋ** អគ្គនាយករងនៃ **ន.ប.ធ.**, **លោក យុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅនៃ **ន.ប.ធ.** និងសហការី បានចុះសួរសុខទុក្ខដល់គេហដ្ឋានរបស់ **លោក ផាន់ ឡូច** ដែលមានភរិយាឈ្មោះ **ហ៊ុំ ស្រី** មានជម្ងឺមហារីកសុដន់ និងលោកស្លូតធ្ងន់ធ្ងរ អស់រយៈពេលជិត ៨ឆ្នាំកន្លងទៅហើយ ក្រោមការសម្របសម្រួលពីអាជ្ញាធរខេត្តតាកែវ ដោយមានការចូលរួមពី **លោក មិញ ហឿន** សមាជិកក្រុមប្រឹក្សាសង្កាត់រការក្នុង និង **អ្នកស្រី ពេជ្រ សុធារី** សមាជិកក្រុមប្រឹក្សាសង្កាត់រការក្នុង ទទួលបន្ទុកកិច្ចការស្ត្រីនិងកុមារ ព្រមទាំងបាននាំនូវសម្ភារៈ គ្រឿងឧបភោគ បរិភោគ និងថវិកាមួយចំនួន ដើម្បីចែកជូនដល់គ្រួសារអ្នកជម្ងឺ ដែលមានទីលំនៅ នៅភូមិស្នោរ សង្កាត់រការក្នុង ខណ្ឌដូនកែវ ខេត្តតាកែវ។



រូបភាព៖ ចុះសួរសុខទុក្ខដល់គេហដ្ឋានរបស់លោក ផាន់ ទូច ដែលមានភរិយាឈ្មោះ ហ៊ូ ស្រី មានជម្ងឺមហារីកសុដន់ និងរលាកសួតធ្ងន់ធ្ងរ។

## អនុស្សរណៈនៃការយោគយល់គ្នា (MoU) រវាង ន.ប.ធ. និងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

នាព្រឹកថ្ងៃចន្ទ ៨ រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២៣ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានចុះអនុស្សរណៈនៃការយោគយល់គ្នា (MoU) ស្តីពី "កិច្ចសហប្រតិបត្តិការលើការលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងការចែករំលែកចំណេះដឹង" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និង **ឯកឧត្តម លី ច័ន្ទតុលា** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងមានការអញ្ជើញចូលរួមជាអធិបតីភាព និងជាសក្ខីភាពដ៏ខ្ពង់ខ្ពស់ពី ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជា នៅទីស្តីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

ការចុះអនុស្សរណៈនៃការយោគយល់គ្នានេះ មានគោលបំណងដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងផ្សព្វផ្សាយពីច្បាប់ និងបទប្បញ្ញត្តិឱ្យបានកាន់តែទូលំទូលាយ ព្រមទាំងផ្តល់កិច្ចសហការចែករំលែកចំណេះដឹងពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច ទៅដល់សមាជិក-សមាជិកា នៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាផងដែរ។

ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នានេះ មានការអញ្ជើញចូលរួមពីតំណាងជាន់ខ្ពស់នៃនិយ័តករ និងអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**), ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃ **ន.ប.ធ.** ថ្នាក់ដឹកនាំ នៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា តំណាងក្រុមហ៊ុនបរធនបាល ប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច និងបរធនបាលរូបវន្តបុគ្គលឯករាជ្យ។



រូបភាព៖ អនុស្សរណៈនៃការយោគយល់គ្នា (MoU) រវាង **ន.ប.ធ.** និងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

## វគ្គបណ្តុះបណ្តាលស្តីពីការរៀបចំសំណើអាជីវកម្ម

នាថ្ងៃអង្គារ ៩រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៣ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាប្រធានគ្រប់គ្រងគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP) សម្រាប់សមាសភាពទី១ (PIU1) **លោក ប៉ូ សំអាង** ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ នៃ **ន.ប.ធ.** និងជាប្រធានផ្នែកប្រតិបត្តិការ នៃគម្រោង ACSEP-PIU1 អមដោយសហការីបានអញ្ជើញចូលរួមជាអធិបតីក្នុងវគ្គបណ្តុះបណ្តាលស្តីពី "ការរៀបចំសំណើអាជីវកម្ម" ដែលបានប្រព្រឹត្តទៅនៅសណ្ឋាគារអង្គរប៉ារ៉ាឌី ខេត្តសៀមរាប។ កម្មវិធីនេះមានការអញ្ជើញចូលរួមដោយលោក-លោកស្រី ដែលជាសមាជិក-សមាជិកានៃអង្គភាពអនុវត្តគម្រោង ACSEP-PIU1 និងក្រុមទីប្រឹក្សាគម្រោង ACSEP-PIU1, តំណាងមកពីមន្ទីរកសិកម្មខេត្តសៀមរាប ព្រះវិហារ និងឧត្តរមានជ័យ, ក្រុមកម្ចីសក្តានុពលពីខេត្តខេត្តសៀមរាប ព្រះវិហារ និងឧត្តរមានជ័យ, តំណាងមកពីធនាគារស្ថាបនា (SPNB) និងធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB)។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888






**រូបភាព៖** វគ្គបណ្តុះបណ្តាលស្តីពី "ការរៀបចំសំណើអាជីវកម្ម"។

## វគ្គបណ្តុះបណ្តាលផ្ទៃក្នុងនិយ័តករបរធនបាលកិច្ចស្តីពី "កាតព្វកិច្ចរាយការណ៍ និងបញ្ជូនករណីសង្ស័យការប្រព្រឹត្តល្មើសពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច"

នាព្រឹកថ្ងៃអង្គារ ៩រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៣ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធន-បាលកិច្ច (**ន.ប.ធ.**), **កញ្ញា ឈាន សុខារី** ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច បានដឹកនាំវគ្គបណ្តុះបណ្តាលផ្ទៃក្នុងនិយ័តករបរធនបាលកិច្ចស្តីពី "កាតព្វកិច្ចរាយការណ៍ និងបញ្ជូនករណីសង្ស័យការប្រព្រឹត្តល្មើសពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច" អមដោយលោក-លោកស្រីប្រធានការិយាល័យ និងមន្ត្រីជំនាញនៃនាយកដ្ឋានក្រោមឱវាទនៃនិយ័តករបរធនបាលកិច្ចដែលមានសមាជិកសរុបចំនួន ២៦ រូប។



**រូបភាព៖** វគ្គបណ្តុះបណ្តាលផ្ទៃក្នុងនិយ័តករបរធនបាលកិច្ចស្តីពី "កាតព្វកិច្ចរាយការណ៍ និងបញ្ជូនករណីសង្ស័យការប្រព្រឹត្តល្មើសពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ច"។

## កិច្ចប្រជុំបច្ចេកទេសនៃអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)

រសៀលថ្ងៃអង្គារ ៩រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **កញ្ញា ឈាង សុខារី** ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច និង**លោក ហាយ សុវណ្ណា** ប្រធានស្តីទីនាយកដ្ឋានចុះបញ្ជីបរធន-បាលកិច្ច បានដឹកនាំសហការីចូលរួមកិច្ចប្រជុំបច្ចេកទេសនៃអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) តាមប្រព័ន្ធអនឡាញ (Zoom) ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សា **អ.ស.ហ.** ដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងប្រកាសស្តីពី "ក្រមសីលធម៌វិជ្ជាជីវៈរបស់ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស" របស់និយ័តករមូលបត្រកម្ពុជា។

កិច្ចប្រជុំនេះ មានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋាន **អ.ស.ហ.** អង្គភាពសវនកម្មផ្ទៃក្នុង និងមន្ត្រីនៃនិយ័តករក្រោមឱវាទ **អ.ស.ហ.**។



រូបភាព៖ កិច្ចប្រជុំបច្ចេកទេសនៃអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)។

## កម្មវិធីជជែកអំពីបរធនបាលកិច្ច៖ ក្រោមប្រធានបទស្ដីពី "បរធនបាលកិច្ច៖ យន្តការសម្រាប់ការវិនិយោគលើអចលនទ្រព្យប្រកបដោយទំនុកចិត្ត"

នាព្រឹកថ្ងៃអង្គារ ២កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣ ដោយអនុវត្តតាមស្មារតីនៃអនុស្សរណៈនៃការយោគយល់គ្នារវាងនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា (HDAC) ស្ដីពី "កិច្ចសហប្រតិបត្តិការលើការលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងជំរុញការចូលរួមក្នុងវិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" **ន.ប.ធ.** និងសមាគម HDAC បានសហការរៀបចំកម្មវិធីបណ្ដុះបណ្ដាល "ជជែកអំពីបរធនបាលកិច្ច" ក្រោមប្រធានបទស្ដីពី "បរធនបាលកិច្ច៖ យន្តការសម្រាប់ការវិនិយោគលើអចលនទ្រព្យប្រកបដោយទំនុកចិត្ត" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និង **អ្នកឧកញ៉ា លី ឃួរ** ប្រធានសមាគមអ្នកភិវឌ្ឍន៍លំនៅឋានកម្ពុជា នៅទីស្នាក់ការសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា។

កម្មវិធីនេះត្រូវបានធ្វើឡើងក្នុងគោលបំណងដើម្បីបញ្ជ្រាបការយល់ដឹងឱ្យបានកាន់តែស៊ីជម្រៅពាក់ព័ន្ធនឹងវិសាលភាព និងគុណប្រយោជន៍នៃយន្តការបរធនបាលកិច្ចដល់ថ្នាក់ដឹកនាំ និងសមាជិក-សមាជិកានៃសមាគម HDAC ដែលជាវិនិយោគិន និងធុរជនសក្ដានុពលក្នុងវិស័យអចលនទ្រព្យនៅកម្ពុជា និងអាចទាញយកផលប្រយោជន៍ជាអតិបរមាពីយន្តការបរធនបាលកិច្ចសម្រាប់ធុរកិច្ចរបស់ខ្លួន។

កម្មវិធីនេះក៏មានការចូលរួមផ្ដល់បទបង្ហាញដោយ **លោក ហាយ សុវណ្ណ** ប្រធានស្ដីទីនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច **លោកស្រី យស ស៊ីវតនា** ប្រធានផ្នែកច្បាប់ និងអនុលោមភាពនៃក្រុមហ៊ុនកាណា ត្រាស និង**លោក ព្រឿង សុភាព** នាយកគ្រប់គ្រងទូទៅនៃក្រុមហ៊ុន ហ្វីលីព ត្រាសធី (ខេមបូឌា)។



រូបភាព៖ កម្មវិធី "ជជែកអំពីបរធនបាលកិច្ច" ក្រោមប្រធានបទស្ដីពី "បរធនបាលកិច្ច៖ យន្តការសម្រាប់ការវិនិយោគលើអចលនទ្រព្យប្រកបដោយទំនុកចិត្ត"។

## វគ្គបណ្ដុះបណ្ដាលស្ដីពីការរៀបចំសំណើអាជីវកម្ម

នាថ្ងៃពុធ ៣កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាប្រធានគ្រប់គ្រងគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP) សម្រាប់សមាសភាពទី១ (PIU1) បានអញ្ជើញចូលរួមជាអធិបតីក្នុងវគ្គបណ្ដុះបណ្ដាលស្ដីពី "ការរៀបចំសំណើអាជីវកម្ម" ដែលបានប្រព្រឹត្តទៅនៅសណ្ឋាគារភ្នំប្រុស ខេត្តកំពង់ចាម។ កម្មវិធីនេះមានការអញ្ជើញចូលរួមដោយ លោក-លោកស្រី ដែលជាសមាជិក-សមាជិកានៃអង្គភាពអនុវត្តគម្រោង ACSEP-PIU1 និងក្រុមទីប្រឹក្សាគម្រោង ACSEP-PIU1, តំណាងមកពីមន្ទីរកសិកម្ម និងក្រុមកម្ចីសក្ដានុពលមកពីខេត្តកំពង់ចាម ត្បូងឃ្មុំ និងកំពង់ធំ, តំណាងមកពីធនាគារស្ថាបនា (SPNB) និងធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB)។វគ្គបណ្ដុះបណ្ដាលនេះមានការចូលរួមពីបុគ្គលិកនៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ដែលជាស្ថាប័នហិរញ្ញវត្ថុដៃគូ និងមន្ត្រីអនុវត្តគម្រោងមកពីនិយ័តករបរធនបាលកិច្ច ដែលជាអង្គភាពអនុវត្តគម្រោង ACSEP សមាសភាគទី១ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលជាអង្គភាពអនុវត្តគម្រោង ACSEP សមាសភាគទី២។



រូបភាព៖ វគ្គបណ្តុះបណ្តាលស្តីពី "ការរៀបចំសំណើរអាជីវកម្ម"។

## កិច្ចប្រជុំប្រមូលធាតុចូលសម្រាប់រៀបចំយន្តការ, លក្ខខណ្ឌ, នីតិវិធី និងបទដ្ឋានគតិយុត្តដើម្បីលើកទឹកចិត្តដល់វិនិយោគិនបរទេសវិនិយោគលើវិស័យអចលនទ្រព្យនៅកម្ពុជា

នារសៀលថ្ងៃពុធ ៣កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **កញ្ញា ឈាន សុខាវី** ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច បានចូលរួមកិច្ចប្រជុំប្រមូលធាតុចូលសម្រាប់រៀបចំយន្តការ, លក្ខខណ្ឌ, នីតិវិធី និងបទដ្ឋានគតិយុត្តដើម្បីលើកទឹកចិត្តដល់វិនិយោគិនបរទេសវិនិយោគលើវិស័យអចលនទ្រព្យនៅកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ថេង ចន្ទសង្វារ** រដ្ឋលេខាធិការក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ នៅទីស្តីការក្រសួង។



រូបភាព៖ កិច្ចប្រជុំប្រមូលធាតុចូលសម្រាប់រៀបចំយន្តការ, លក្ខខណ្ឌ, នីតិវិធី និងបទដ្ឋានគតិយុត្តដើម្បីលើកទឹកចិត្តដល់វិនិយោគិនបរទេសវិនិយោគលើវិស័យអចលនទ្រព្យនៅកម្ពុជា។

## ពិធីពិព័រណ៍ផ្សារភាគហ៊ុនកម្ពុជា "My First STOCK" ប្រចាំឆ្នាំ២០២៣

នាព្រឹកថ្ងៃព្រហស្បតិ៍ ៤កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានអញ្ជើញចូលរួមក្នុងពិធីពិព័រណ៍ផ្សារភាគហ៊ុនកម្ពុជា "My First STOCK" ប្រចាំឆ្នាំ២០២៣ ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃផ្សារមូលបត្រកម្ពុជា ដែលធ្វើឡើងនៅផ្សារទំនើបអ៊ីអន១ភ្នំពេញ។



រូបភាព៖ ពិធីពិព័រណ៍ផ្សារភាគហ៊ុនកម្ពុជា "My First STOCK" ។

## សិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការដាក់ឱ្យអនុវត្តជាផ្លូវការម៉ាស៊ីនមេ សម្រាប់ការប្រើប្រាស់ផ្ទៃក្នុងរបស់ ន.ប.ធ." និងសេចក្តីណែនាំស្តីពី "ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងឯកសាររបស់ ន.ប.ធ." ក្នុងក្របខណ្ឌនៃការអនុវត្តសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM) ប្រចាំឆ្នាំ២០២៣

ព្រឹកថ្ងៃសុក្រ ៥កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៣ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**), និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការដាក់ឱ្យអនុវត្តជាផ្លូវការម៉ាស៊ីនមេ សម្រាប់ការប្រើប្រាស់ផ្ទៃក្នុងរបស់ **ន.ប.ធ.**"

ទំព័រទី៦

និងសេចក្តីណែនាំស្តីពី "ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងឯកសាររបស់ **ន.ប.ធ.**" ក្នុងក្របខណ្ឌនៃការអនុវត្តសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយឯកឧត្តមអគ្គនាយករង និងប្រធាននាយកដ្ឋាននៃ **ន.ប.ធ.** ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅសណ្ឋាគារសង្គហៈមិត្ត ខេត្តកែប ព្រមទាំងផ្សារភ្ជាប់ជាមួយនឹងកម្មវិធីកសាងសមត្ថភាពមន្ត្រីនៃ **ន.ប.ធ.** ស្តីពី "ការចែករំលែកចំណេះដឹង និងបទពិសោធន៍ពាក់ព័ន្ធនឹងយន្តការ និងនីតិវិធីនៃការសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថល (Digital KYC and e-Signature)" ដែលធ្វើបទបង្ហាញដោយមន្ត្រីជាន់ខ្ពស់ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX) នៃមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" ផងដែរ។ សិក្ខាសាលាផ្សព្វផ្សាយនេះ មានការចូលរួមពីឯកឧត្តមអគ្គរង, ប្រធាននាយកដ្ឋាន និងមន្ត្រីនៃ **ន.ប.ធ.** ទាំងអស់ ព្រមទាំងមានការចូលរួមនិងផ្តល់បទបង្ហាញដោយមន្ត្រីជាន់ខ្ពស់របស់ CamDX នៃមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ"។

សិក្ខាសាលាផ្សព្វផ្សាយនេះ រៀបចំឡើងក្នុងគោលបំណងដើម្បីបញ្ជ្រាបការយល់ដឹងបន្ថែមឱ្យបានកាន់តែទូលំទូលាយដល់ថ្នាក់ដឹកនាំ និងមន្ត្រីនៃ **ន.ប.ធ.** អំពីដំណើរការ និងនីតិវិធីប្រើប្រាស់ម៉ាស៊ីន Server ប្រកបដោយ ប្រសិទ្ធភាព និងមានសុវត្ថិភាពខ្ពស់ ក៏ដូចជាការអនុវត្តប្រព័ន្ធគ្រប់គ្រងឯកសាររបស់ **ន.ប.ធ.** ដែលមានដំណើរការនៅលើបណ្តាញអ៊ីនត្រាណេតផ្ទៃក្នុងរបស់ **ន.ប.ធ.** និងការសិក្សារៀនសូត្របន្ថែមទៅលើយន្តការ និងនីតិវិធីនៃការកំណត់ពីអត្តសញ្ញាណអតិថិជនឌីជីថល (Digital KYC and e-Signature)។




**រូបភាព៖** សិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការដាក់ឱ្យអនុវត្តជាផ្លូវការម៉ាស៊ីនមេសម្រាប់ការប្រើប្រាស់ផ្ទៃក្នុងរបស់ ន.ប.ធ." និងសេចក្តីណែនាំស្តីពី "ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងឯកសាររបស់ **ន.ប.ធ.**" ក្នុងក្របខណ្ឌនៃការអនុវត្តសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM) ប្រចាំឆ្នាំ២០២៣។

## កិច្ចប្រជុំពិភាក្សាជាមួយមជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech Center)

នាព្រឹកថ្ងៃចន្ទ ៨កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានដឹកនាំកិច្ចប្រជុំពិភាក្សាជាមួយមជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech Center) នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) តំណាងដោយ **លោក ខេង ចន្ថា** និង **លោកស្រី ឈុន សុភា** មន្ត្រីជំនាញជាន់ខ្ពស់ FinTech Center នៃអគ្គលេខាធិការដ្ឋាន **អ.ស.ហ.** ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងគោលការណ៍ណែនាំស្តីពី "បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យបរធនបាលកិច្ច" របស់និយ័តករបរធនបាលកិច្ច។

កិច្ចប្រជុំនេះ បានរៀបចំឡើងក្នុងគោលបំណងដើម្បីពិនិត្យ ក៏ដូចជាទទួលបានធាតុចូលក្នុងកម្រិតបច្ចេកទេសបន្ថែមពី FinTech Center នៃអគ្គលេខាធិការដ្ឋាន **អ.ស.ហ.** ដើម្បីឱ្យការរៀបចំសេចក្តីព្រាងគោលការណ៍ណែនាំនេះកាន់តែមានលក្ខណៈពេញ-លេញ និងគ្រប់ជ្រុងជ្រោយ ដែលសំដៅដល់ការអនុវត្តប្រកបដោយសណ្តាប់ធ្នាប់ តម្លាភាព ប្រសិទ្ធភាព និងទំនុកចិត្តពីគ្រប់តួអង្គ និងអ្នកចូលរួមក្នុងវិស័យបរធនបាលកិច្ច។




**រូបភាព៖** កិច្ចប្រជុំពិភាក្សាជាមួយមជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech Center)។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីពិនិត្យ និងពិភាក្សាលើរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសទី៣ ឆ្នាំ២០២៣

ព្រឹកថ្ងៃអង្គារ ៩កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **ឯកឧត្តម ណី សាគល** អគ្គនាយករងនៃ **ន.ប.ធ.**, **លោក យុន វ៉ាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅនៃ **ន.ប.ធ.** និងសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីពិនិត្យ និងពិភាក្សាលើរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសទី៣ ឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំស្ថាប័ន អង្គភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិ តាមប្រព័ន្ធអនឡាញ Zoom។



រូបភាព៖ កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីពិនិត្យ និងពិភាក្សាលើរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសទី៣ ឆ្នាំ២០២៣។

## សិក្ខាសាលាស្ដីពី ការរៀបចំ និងការលើកទឹកចិត្តគម្រោងចំណតសាធារណៈ

ព្រឹកថ្ងៃពុធ ១០កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញចូលរួមសិក្ខាសាលាស្ដីពី ការរៀបចំ និងការលើកទឹកចិត្តគម្រោងចំណតសាធារណៈ ក្រោមអធិបតីភាព**ឯកឧត្តម ពេជ្រ សម្បត្តិ** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការអញ្ជើញចូលរួមពីតំណាងសភាពាណិជ្ជកម្មកម្ពុជា, តំណាងវិស័យឯកជន និងអ្នកពាក់ព័ន្ធដទៃទៀត។

នៅក្នុងសិក្ខាសាលានេះ ឯកឧត្តមបានផ្ដល់មតិជាធាតុចូលអំពីយន្តការមួយចំនួនដែលជាជម្រើសក្នុងការវិនិយោគលើគម្រោងចំណតសាធារណៈ ក្នុងនោះយន្តការបរធនបាលកិច្ច ជាជម្រើសមួយដ៏សំខាន់ដែលអាចអនុញ្ញាតឱ្យវិនិយោគិនក្នុងស្រុក និងបរទេសអាចធ្វើការវិនិយោគប្រកបដោយទំនុកចិត្ត។



រូបភាព៖ សិក្ខាសាលាស្ដីពី ការរៀបចំ និងការលើកទឹកចិត្តគម្រោងចំណតសាធារណៈ។

## ប្រជុំពិភាក្សាការងាររវាង ន.ប.ធ. និងក្រុមហ៊ុន TrustQuay

ព្រឹកថ្ងៃព្រហស្បតិ៍ ១១កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ**២០២៣ ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញទទួលជួបប្រជុំពិភាក្សាការងារជាមួយក្រុមហ៊ុន TrustQuay តំណាងដោយ**លោក** Ryan Pang ប្រធានផ្នែកអភិវឌ្ឍន៍ធុរកិច្ចនៃក្រុមហ៊ុន TrustQuay តាមប្រព័ន្ធអនឡាញ។

កិច្ចប្រជុំនេះមានការធ្វើបទបង្ហាញដោយ**លោក**Ryan Pang អំពីដំណើរការនៃប្រព័ន្ធ ក៏ដូចជាការបង្ហាញពីប្រព័ន្ធគ្រប់គ្រងប្រតិបត្តិការបរធនបាលកិច្ចស្របតាមឧត្តមានុវត្តន៍អន្តរជាតិនៃប្រតិបត្តិការបរធនបាលកិច្ចដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យា។



**រូបភាព៖** ប្រជុំពិភាក្សាការងារជាមួយក្រុមហ៊ុន TrustQuay។

## កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្ដីព្រាងគោលការណ៍ណែនាំស្ដីពី "បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យបរធនបាលកិច្ច"

ព្រឹកថ្ងៃសុក្រ ១២កើត ខែកត្ដិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅទីស្ដីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**), និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់លើសេចក្ដីព្រាងគោលការណ៍ណែនាំស្ដីពី "បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យបរធនបាលកិច្ច"ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយ ឯកឧត្តមអគ្គនាយករង ប្រធាននាយកដ្ឋាន និងសហការីនៃ **ន.ប.ធ.** ដោយមានការចូលរួមពីតំណាងមកពី៖ (១).គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល, (២).មជ្ឈមណ្ឌលបណ្ដុះធុរកិច្ចថ្មី "តេជោ", (៣).និយ័តករ និងអង្គភាពក្រោមឱវាទនៃ **អ.ស.ហ.** និង (៤).តួអង្គ និងបុគ្គលពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច និងបុគ្គលពាក់ព័ន្ធផ្សេងទៀត។

កិច្ចប្រជុំនេះ រៀបចំឡើងក្នុងគោលបំណងទទួលបានមតិយោបល់ និងធាតុចូលបន្ថែមពីភាគីពាក់ព័ន្ធទាំងអស់ ដើម្បីឱ្យសេចក្ដី-ព្រាងគោលការណ៍ណែនាំនេះកាន់តែមានលក្ខណៈពេញលេញ និងគ្រប់ជ្រុងជ្រោយ ដែលសំដៅដល់ការអនុវត្តប្រកបដោយប្រសិទ្ធភាពតម្លាភាព និងទំនុកចិត្តពីអ្នកចូលរួមនៅក្នុងវិស័យបរធនបាលកិច្ច។

កិច្ចប្រជុំពិគ្រោះយោបល់នេះក៏មានការធ្វើបទបង្ហាញដោយ **លោក ចេស ចាន់ដេត** ប្រធានការិយាល័យគ្រប់គ្រងព័ត៌មានវិទ្យានៃនាយកដ្ឋានកិច្ចការទូទៅ អំពីខ្លឹមសារជារួមដែលមាននៅក្នុងសេចក្ដីព្រាងគោលការណ៍ណែនាំនេះផងដែរ។



**រូបភាព៖** កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្ដីព្រាងគោលការណ៍ណែនាំស្ដីពី "បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុង វិស័យបរធនបាលកិច្ច"។

## កិច្ចប្រជុំស្ដីពីការរៀបចំផែនការសកម្មភាព និងថវិកាសម្រាប់ឆ្នាំ២០២៤

នារសៀលថ្ងៃសុក្រ ១២កើត ខែកត្ដិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៣ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាប្រធានគ្រប់គ្រងគម្រោង ACSEP សម្រាប់សមាសភាគទី១ (PIU1), ក្រុមការងារនៃ **ន.ប.ធ.** ដែលជាអង្គភាពអនុវត្តគម្រោងសមាសភាគទី១ នៃគម្រោង ACSEP រួមមាន៖ **លោក ប៉ូ សំអាង** ប្រធានផ្នែកប្រតិបត្តិការ, **លោក ហាយ សុវណ្ណា** ប្រធានផ្នែកគណនេយ្យនិងហិរញ្ញវត្ថុ និងក្រុមទីប្រឹក្សាជាតិ និងសហការី បានចូលរួមកិច្ចប្រជុំពីចម្ងាយស្ដីពីការរៀបចំផែនការសកម្មភាព និងថវិកាសម្រាប់ឆ្នាំ២០២៤ របស់អង្គភាពអនុវត្តគម្រោងសមាសភាគទី១ នៃគម្រោង ACSEP តាមប្រព័ន្ធអនឡាញ Zoom ក្រោមការដឹកនាំរបស់ **លោកបណ្ឌិត សរ ចិន្ត្រា** នាយកគម្រោងនៃអង្គភាពគ្រប់គ្រងគម្រោង និងជាអង្គភាពអនុវត្តគម្រោងសមាសភាគទី២ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមានការចូលរួមពីអង្គភាពអនុវត្តគម្រោងសមាស-ភាគទី៣ នៃក្រសួងអភិវឌ្ឍន៍ជនបទ និងភាគីពាក់ព័ន្ធផងដែរ។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888



រូបភាព៖ កិច្ចប្រជុំពិចម្ងាយស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាសម្រាប់ឆ្នាំ២០២៤។

## កម្មវិធីសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ផែនការសកម្មភាពបីឆ្នាំរំកិល ២០២៣-២០២៥ របស់និយ័តករបរធនបាលកិច្ច៖ ការវាយតម្លៃការអនុវត្ត និងទិសដៅការងារបន្ត" និងកម្មវិធីកសាងសមត្ថភាពមន្ត្រី"

ព្រឹកថ្ងៃពុធ ២រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៣ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ក្នុងក្របខណ្ឌនៃការអនុវត្តសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំកម្មវិធីសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ផែនការសកម្មភាពបីឆ្នាំរំកិល ២០២៣-២០២៥ របស់និយ័តករបរធនបាលកិច្ច៖ ការវាយតម្លៃការអនុវត្ត និងទិសដៅការងារបន្ត" និងកម្មវិធីកសាងសមត្ថភាពមន្ត្រី" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយឯកឧត្តមអគ្គនាយករង និងប្រធាននាយកដ្ឋាន ព្រមទាំងមន្ត្រីទាំងអស់នៃ **ន.ប.ធ.** ដែលប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៩-៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅសណ្ឋាគារ អេមព្រីសអង្គរ ខេត្តសៀមរាប។



រូបភាព៖ កម្មវិធីសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ផែនការសកម្មភាពបីឆ្នាំរំកិល ២០២៣-២០២៥ របស់និយ័តករបរធនបាលកិច្ច៖ ការវាយតម្លៃការអនុវត្ត និងទិសដៅការងារបន្ត" និងកម្មវិធីកសាងសមត្ថភាពមន្ត្រី"។

## កម្មវិធីការងារសង្គមនៅ "មជ្ឈមណ្ឌលកុមារកំព្រាខេត្តសៀមរាប"

នៅថ្ងៃព្រហស្បតិ៍ ៣រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំកម្មវិធីការងារសង្គមនៅ "មជ្ឈមណ្ឌលកុមារកំព្រាខេត្តសៀមរាប" នៃខេត្តសៀមរាប ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** រួមដំណើរជាមួយដោយ **ឯកឧត្តមអគ្គនាយករង នង ពិសិដ្ឋ** និង**ឯកឧត្តម ឈី សាគល**, ថ្នាក់ដឹកនាំនាយកដ្ឋាននិងសហការីនៃ **ន.ប.ធ.** ដោយបានពាំនាំយកនូវអំណោយសប្បុរសធម៌ជាគ្រឿងឧបភោគបរិភោគ និងសម្ភារៈមួយចំនួនដូចជា៖ សម្ភារៈសិក្សា សម្ភារៈកីឡា ថ្នាំពេទ្យនិងប្រអប់សង្គ្រោះបឋម សាប៊ូ ច្រាសនិងថ្នាំដុសធ្មេញ អង្ករ មី ត្រីងៀត ត្រីខ ភេសជ្ជៈ ព្រមទាំងគ្រឿងឧបភោគបរិភោគផ្សេងៗទៀត ក៏ដូចជាអាហារសម្រន់ផងដែរ ដើម្បីចែកជូនប្អូនៗកុមារ និងមន្ត្រីបម្រើការងារនៅក្នុងមជ្ឈមណ្ឌល។

នាឱកាសនេះដែរ **ឯកឧត្តម សុខ ដារ៉ា** ក៏បានសំណេះ-សំណាល សម្តែងការកោតសរសើរ ក៏ដូចជាផ្តល់ការលើកទឹកចិត្ត និងចែករំលែកបទពិសោធន៍ជីវិតដល់ប្អូនៗកុមារ ឱ្យខិតខំសិក្សា និងតស៊ូប្រឹងប្រែងដើម្បីអនាគតរបស់ខ្លួន និងដើម្បីក្លាយជាទំពាំងស្នងឬស្សីដ៏រឹងមាំរបស់សង្គមនាពេលអនាគត។

កម្មវិធីការងារសង្គមនេះត្រូវបានបញ្ចប់ដោយរលូន ក្រោមបរិយាកាសរីករាយ ស្និទ្ធស្នាល និងពោរពេញទៅដោយស្នាមញញឹមនិងក្តីស្រលាញ់។





រូបភាព៖ កម្មវិធីការងារសង្គមនៅ "មជ្ឈមណ្ឌលកុមារកំព្រាខេត្តសៀមរាប"។

## កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.) ដើម្បីពិនិត្យលើខ្លឹមសារនៃសេចក្ដីព្រាងផែនការអភិវឌ្ឍន៍ស្ថាប័ននិយ័តករគណនេយ្យនិងសវនកម្មសម្រាប់រយៈពេល១០ឆ្នាំ (២០២១-២០៣០)

រសៀលថ្ងៃព្រហស្បតិ៍ ៣រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៣ **លោក ប៉ូ សំអាង** ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ និង **លោក ណង សេរីវុធ** អនុប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះ-បណ្តាល និងសហប្រតិបត្តិការ អមដោយសហការី បានចូលរួមកិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដើម្បីពិនិត្យលើខ្លឹមសារនៃសេចក្ដីព្រាងផែនការអភិវឌ្ឍន៍ស្ថាប័ននិយ័តករគណនេយ្យនិងសវនកម្មសម្រាប់រយៈពេល១០ឆ្នាំ (២០២១-២០៣០) ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** អនុប្រធាន **អ.ស.ហ.** តាមរយៈកិច្ចសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាននៃ **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ (Zoom)។



រូបភាព៖ កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.) ដើម្បីពិនិត្យលើខ្លឹមសារនៃសេចក្ដីព្រាងផែនការអភិវឌ្ឍន៍ស្ថាប័ននិយ័តករគណនេយ្យនិងសវនកម្មសម្រាប់រយៈពេល១០ឆ្នាំ (២០២១-២០៣០)។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888